WWF for a living planet®

**WWF-Cambodia**

21, Street 322,
Boeung Keng Kang I,
Phnom Penh, Cambodia

P.O. Box: 2467
Tel: +855 23 218 034
Fax: +855 23 211 909

www.cambodia.panda.org

| **Press Release** | **For immediate release** |
|---|---|

# **អង្គការ** WWF **អបអរសាទរនៃការចាប់កំណើតកូនផ្សោតចំនួន២ក្បាល**

**ភ្នំពេញ ថ្ងៃទី១៥ សីហា ឆ្នាំ២០១៧** – អង្គការ WWF-កម្ពុជា សូមស្វាគមន៍នៃវត្តមានកូនផ្សោតថ្មីចំនួន២ក្បាល នៅក្នុងតំបន់ទេសភាពព្រៃលិចទឹកមេគង្គ ស្ថិតក្នុងខេត្តក្រចេះ។ កូនផ្សោតទី១ ត្រូវបានគេប្រទះឃើញនៅថ្ងៃទី១១ ខែសីហា ហើយភ្លាមៗនោះក្រុមការងារសហគមន៍ដែលរស់នៅភូមិព្រែកគ្រៀង ឃុំវឌ្ឍនៈ ស្រុកសំបូរ ក៏បានធ្វើសេចក្តីរាយការណ៍មកកាន់ក្រុមការងាររបស់អង្គការ WWF ។

មន្ត្រីផ្នែកជំនួយការគម្រោងទឹកស្អាត លោក តាន់ ប៊ុនវឌ្ឍន៍ បានចុះទៅដល់ទីតាំងភ្លាមៗដើម្បីថតរូបកូនផ្សោតទី១ ដែលតាមការប៉ាន់ប្រមាណ គឺកូនផ្សោតនេះមានអាយុប្រហែលជា ៣សប្តាហ៍។ រីឯកូនផ្សោតមួយទៀត គឺទើបតែកើតបានប៉ុន្មានថ្ងៃនេះប៉ុណ្ណោះ នេះបើតាមការឲ្យដឹងពីអ្នកភូមិដែលរស់នៅទីនោះ និងក្រុមការងារស្រាវជ្រាវរបស់អង្គការ WWF-កម្ពុជា នៅម្តុំអន្លង់កាំពីដែលមានចម្ងាយប្រមាណ១៦គីឡូម៉ែត្រពីទីក្រុងក្រចេះ។

តាមរយៈលទ្ធផលទាំងនេះ គឺបានបង្ហាញពីសញ្ញាវិជ្ជមានការកើនឡើងចំនួនរបស់សត្វផ្សោតទន្លេមេគង្គ។ គួរបញ្ជាក់ផងដែរថា នៅដើមឆ្នាំនេះចាប់ពីខែមករាដល់ខែសីហា មានកូនផ្សោតកើតថ្មីទាំងអស់ចំនួន៨ក្បាល់ត្រូវបានកត់ត្រា ហើយក្នុងនោះក៏មានកូនផ្សោតចំនួន២ក្បាលដែរដែលបានស្លាប់ ។ កិច្ចខិតខំប្រឹងប្រែងទាំងនេះ គឺជាជោគជ័យដ៏ធំមួយ បើប្រៀបធៀបក្នុងរយៈកាលដូចគ្នាកាលពីឆ្នាំ២០១៦ បានបង្ហាញថា មានកូនផ្សោតកើតថ្មី៩ក្បាល ហើយស្លាប់ទៅវិញ៩ក្បាល។ តាមរយៈលទ្ធផលនេះ ក្រុមការងារអភិរក្សរបស់យើង សង្ឃឹមយ៉ាងមុតមាំថា យើង មានលទ្ធភាពដើម្បីកាត់បន្ថយការធ្លាក់ចុះនៃចំនួនសត្វផ្សោតក្នុងកម្រិតអតិបរមាដើម្បីអោយចំនួនសរុបរបស់វាមានការកើនឡើង។

លោក សេង ទៀក នាយកប្រចាំប្រទេសនៃអង្គការ WWF-កម្ពុជា បាននិយាយថា ៖"យើងទាំងអស់គ្នាពិតជារីករាយខ្លាំងបំផុត ចំពោះលទ្ធផលនៃភាពជោគជ័យទាំងនេះតាមរយៈការកើតកូនផ្សោតថ្មីចំនួន២ក្បាលទៀត។ ជាក់ស្តែង វាជាការងារដែលយើងបានខិតខំទាំងអស់គ្នា ជាពិសេសនោះគឺ

មន្ត្រីឆ្មាំទន្លេរបស់យើង ដែលបំពេញការងារដោយមិនខ្លាចនឿយហត់ឡើយ ដើម្បីការពារសត្វផ្សោត និងធនធានជលផលទាំងអស់។"

សូមបញ្ជាក់ថា កត្តាគំរាមកំហែងដ៏ធំធុតចំពោះសត្វផ្សោត ជាពិសេស គឺកូនផ្សោតនោះ គឺពាក់ព័ន្ធទៅនឹង ការនេសាទខុសច្បាប់គ្រប់ប្រភេទ កម្រិតទឹកទន្លេមានការធ្លាក់ចុះ ការបំពុលទឹកទន្លេ និងគម្រោងសាងសង់ទំនប់វារីអគ្គិសនីនៅតាមដងទន្លេមេរបស់ទន្លេមេគង្គ។ សត្វផ្សោតទន្លេ មេគង្គគឺជាសម្បត្តិធម្មជាតិមានជីវិតរបស់ប្រទេសកម្ពុជា ហើយបច្ចុប្បន្នចំនួនរបស់វាមានប្រមាណ៨០ក្បាលរស់នៅក្នុងទន្លេមេគង្គរបស់យើង ហើយត្រូវបានចាត់ទុកជាក្រុមប្រភេទសត្វជិតផុតពូជរបស់អង្គការ IUCN។

អង្គការ WWF-កម្ពុជា បានកំពុងអនុវត្តគម្រោងអភិរក្សសត្វផ្សោតទន្លេមេគង្គយ៉ាងខ្ជាប់ខ្ជួនតាំងតែពីឆ្នាំ២០០៧ មកម្ល៉េះ ក្នុងគោលបំណងកាត់បន្ថយអត្រាស្លាប់របស់សត្វផ្សោត និងបង្កើនចំនួនរបស់ពួកវាឡើងវិញ តាមរយៈការពង្រឹងការអនុវត្តន៍ច្បាប់ ការងារអប់រំផ្សព្វផ្សាយតាមសហគមន៍ ការបង្កើនកម្រិតជីវភាពរបស់សហគមន៍ឲ្យកាន់តែប្រសើរឡើង ការសិក្សាស្រាវជ្រាវ អង្កេត និងតាមដាន និងពង្រឹងកិច្ចសហប្រតិបត្តិការព្រំដែនរវាងប្រទេសកម្ពុជា និងឡាវ។

###


**សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនង៖**

លោក អ៊ុន ចក្រី ប្រធានផ្នែកទំនាក់ទំនងរបស់អង្គការ WWF-កម្ពុជា

ទូរស័ព្ទ : +855 (0)១៧ ២៣៤ ៥៥៥

Email: Chakrey.un@wwfgreatermekong.org


## អំពីអង្គការ WWF-កម្ពុជា

អង្គការWWF បានបង្កើតឡើងនៅក្នុងប្រទេសកម្ពុជាក្នុងឆ្នាំ១៩៩៥ដែលជាផ្នែកមួយនៃអង្គការWWF ក្នុងមហាតំបន់ទន្លេមេគង្គ។ បេសកកម្មរបស់អង្គការWWF គឺធានាឲ្យមានការចូលរួមគាំទ្រពីមនុស្សគ្រប់រូបដើម្បីធ្វើការអភិរក្សនូវជីវចម្រុះដ៏សម្បូរបែបនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ អង្គការWWF-កម្ពុជា នឹងជម្រុញឲ្យមានឱកាសថ្មីៗជាច្រើនដែលផ្តល់ផលប្រយោជន៍ដល់មនុស្ស និងធ្វើឲ្យប្រសើរឡើងនូវកម្រិតជីវភាពរបស់នៅរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន ព្រមទាំងចូលរួមកាត់បន្ថយភាពក្រីក្រតាមរយៈការលើកទឹកចិត្តឲ្យមានការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាព។ សម្រាប់ព័ត៌មានលំអិតសូមចូលទៅកាន់គេហទំព័ររបស់អង្គការWWF-កម្ពុជា cambodia.panda.org